**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៣៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងមូលនិធិបំពេញផលហិរញ្ញវត្ថុ
# សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.**_

អនុក្រឹត្យនេះមានគោលបំណងកំណត់បែបបទ និងនីតិវិធីនៃការគ្រប់គ្រង **"មូលនិធិបំពេញផលហិរញ្ញវត្ថុ"** ដែលសរសេរជាអក្សរកាត់ថា **"ម.ប.ហ."** ដែលបានបង្កើតឡើងដោយច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន(**ភ.រ.ជ.**)។

**មាត្រា២.**_

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងគម្រោងសេវាសាធារណៈទាំងឡាយអនុវត្តតាមយន្តការ**ភ.រ.ជ.** និងគម្រោងអាទិភាពរបស់រាជរដ្ឋាភិបាលដែលមានការចូលរួមពីវិស័យឯកជន។

**មាត្រា៣.**_

វាក្យសព្ទសំខាន់ៗដែលប្រើសម្រាប់គោលដៅនៃអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**១. ការគាំទ្រពីរដ្ឋ** សំដៅដល់ជំនួយហិរញ្ញវត្ថុនិងជំនួយមិនមែនហិរញ្ញវត្ថុដែលរដ្ឋផ្តល់ដើម្បីគាំទ្រការអនុវត្តគម្រោង**ភ.រ.ជ.**។ ការគាំទ្រពីរដ្ឋមានជាអាទិ៍ថវិកាសម្រាប់គម្រោងផ្ទាល់ដែលរាជរដ្ឋាភិបាលជានាចំណាយ (ដូចជាការឧបត្ថម្ភធន) កាតព្វកិច្ចបំណុលជាយថាហេតុ (ដូចជាកិច្ចធានាផ្សេងៗ) វិភាគទានជាទ្រព្យសម្បត្តិរដ្ឋនិងជំនួយក្នុងទម្រង់ផ្សេងទៀត។

**២.ការបំពេញផលហិរញ្ញវត្ថុ** សំដៅដល់ការគាំទ្រពីរដ្ឋមួយប្រភេទដែលជាការឧបត្ថម្ភធនដោយផ្ទាល់ដល់ការចំណាយមូលធនក្រោមក្របខ័ណ្ឌគម្រោង**ភ.រ.ជ.** ដើម្បីបង្កើនផលចំណេញផ្នែកហិរញ្ញវត្ថុរបស់គម្រោងនោះចំពោះដៃគូឯកជន។

**៣.គណនីរក្សាទុក** សំដៅដល់សេវារក្សាសុវត្ថិភាពនិងដំណើរការទ្រព្យសកម្មហិរញ្ញវត្ថុ រួមទាំងសកម្មភាពពាក់ព័ន្ធផ្សេងទៀត ដូចជាគណនីអែសស្រ្កូ។

**៤. ដៃគូឯកជន** សំដៅដល់បុគ្គលដែលបានចុះកិច្ចសន្យា**ភ.រ.ជ.** ជាមួយស្ថាប័នសាមី។ ក្នុងករណីក្រុមហ៊ុនមានគោលបំណងពិសេស ត្រូវបានបង្កើតឡើងដោយអនុលោមតាមមាត្រា២២ នៃច្បាប់ស្តីពី**ភ.រ.ជ.** ដៃគូឯកជនសំដៅដល់ក្រុមហ៊ុនមានគោលបំណងពិសេសនេះវិញ។

**៥. ទីប្រឹក្សាឯករាជ្យ** សំដៅដល់ក្រុមហ៊ុនទីប្រឹក្សា ដែលនឹងត្រូវជ្រើសរើសឱ្យចូលរួមបំពេញការងារដោយស្ថាប័នសាមី ហើយជាទូទៅហិរញ្ញប្បទានដោយដៃគូឯកជន ដើម្បីផ្តល់សេវាកម្មប្រកបដោយភាពឯករាជ្យ ក្នុងការពិនិត្យ តាមដាន អនុម័ត និងរាយការណ៍អំពីការអនុវត្តគម្រោង ប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ស្របតាមកិច្ចសន្យា**ភ.រ.ជ.**។

**៦. ទុនមូលធន** សំដៅដល់ដើមទុន ដែលដៃគូឯកជនបានរួមចំណែកទៅក្នុងទុនវិនិយោគគម្រោងសរុប។

**៧. ទុនវិនិយោគគម្រោងសរុប** សំដៅដល់ទុនសរុបជារូបិយវត្ថុ ឬរូបិយប័ណ្ណបរទេស ដែលបានវិនិយោគនៅក្នុងក្រុមហ៊ុនមានគោលបំណងពិសេស ដោយរួមបញ្ចូលមូលធន បំណុលមានអាទិភាពខ្ពស់និងបំណុលបន្ទាប់បន្សំ ព្រមទាំងការគាំទ្រពីរដ្ឋ លើកលែងថ្លៃដី ឬទ្រព្យសកម្មរយៈពេលវែងផ្សេងៗដែលទទួលបានពីរដ្ឋ។

**៨. ពិតានថវិកានៃកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈសម្រាប់កម្មវិធីភ.រ.ជ.** សំដៅដល់ការកំណត់ទំហំអតិបរមានៃកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈសម្រាប់គម្រោង**ភ.រ.ជ.** ទាំងអស់ ដែលរួមមាន កាតព្វកិច្ចហិរញ្ញវត្ថុត្រូវទូទាត់ផ្ទាល់ (ការបំពេញផលហិរញ្ញវត្ថុ និងការទូទាត់ថ្លៃសេវាផ្អែកលើថវិការដ្ឋ) និងកាតព្វកិច្ចបំណុលជាយថាហេតុកើតចេញពីគម្រោង**ភ.រ.ជ.**។

**៩. ពិតាននៃការបំពេញផលហិរញ្ញវត្ថុ** សំដៅដល់ការកំណត់ទំហំអតិបរមានៃការបំពេញផលហិរញ្ញវត្ថុសម្រាប់គម្រោង**ភ.រ.ជ.** ដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ។

**១០. វិនិយោគិន** សំដៅដល់បុគ្គល ដែលផ្តល់ហិរញ្ញប្បទានជាភាគទុនដល់ដៃគូឯកជន ដើម្បីអនុវត្តកិច្ចសន្យា**ភ.រ.ជ.** ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## យន្តការស្ថាប័ន

### មាត្រា៤._

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាស្ថាប័នមានសមត្ថកិច្ចក្នុងការដឹកនាំ និងគ្រប់គ្រង**ម.ប.ហ.**។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន ជាសេនាធិការ ក្នុងការរៀបចំ គ្រប់គ្រង និងប្រតិបត្តិការ**ម.ប.ហ.** នេះ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវសុំការសម្រេចពីរាជរដ្ឋាភិបាលលើការប្រើប្រាស់**ម.ប.ហ.** បន្ទាប់ពីការវាយតម្លៃលើតម្រូវការការបំពេញផលហិរញ្ញវត្ថុរបស់គម្រោង**ភ.រ.ជ.** និង/ឬការគាំទ្រផ្នែកវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈរបស់គម្រោងអាទិភាពរបស់រាជរដ្ឋាភិបាលដែលមានការចូលរួមពីវិស័យឯកជន។

### មាត្រា៥._

បន្ថែមពីតួនាទីនិងភារកិច្ច ដែលប្រគល់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបំពេញមុខងារពាក់ព័ន្ធនឹងការដឹកនាំ និងគ្រប់គ្រង**ម.ប.ហ.** ដូចខាងក្រោម៖

- ពិនិត្យ និងឯកភាពជាគោលការណ៍លើការគាំទ្របំពេញផលហិរញ្ញវត្ថុសម្រាប់គម្រោង**ភ.រ.ជ.** មុននឹងចាប់ផ្តើមដំណើរការកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជន ដែលដឹកនាំដោយស្ថាប័នសាមី
- ពិនិត្យ និងកំណត់ពិតាននៃការបំពេញផលហិរញ្ញវត្ថុ មិនឱ្យលើសពីទំហំអតិបរមា ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ សម្រាប់គម្រោង**ភ.រ.ជ.** នីមួយៗ ទៅតាមដំណាក់កាលនៃកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជន ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ពិនិត្យ និងឯកភាពជាគោលការណ៍លើការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធសាធារណៈរបស់គម្រោងអាទិភាពរបស់រាជរដ្ឋាភិបាលដែលមានការចូលរួមពីវិស័យឯកជន។

**មាត្រា៦.**_

បន្ថែមពីតួនាទីនិងភារកិច្ច ដែលប្រគល់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ស្ថាប័នសាមីត្រូវបំពេញមុខងារពាក់ព័ន្ធ ដូចខាងក្រោម៖

- ចាត់ចែងឱ្យមានទីប្រឹក្សាឯករាជ្យ ដើម្បីផ្ទៀងផ្ទាត់ការស្នើសុំការបំពេញផលហិរញ្ញវត្ថុរបស់ដៃគូឯកជនផ្អែកតាមវឌ្ឍនភាពនៃការអនុវត្តគម្រោង**ភ.រ.ជ.**
- លើកសំណើស្នើសុំថវិកាប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធសាធារណៈរបស់គម្រោងអាទិភាពរបស់រាជរដ្ឋាភិបាល ដែលមានការចូលរួមពីវិស័យឯកជន
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរៀបចំរបាយការណ៍ពាក់ព័ន្ធលើការអនុវត្តការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធសាធារណៈរបស់គម្រោងអាទិភាពរបស់រាជរដ្ឋាភិបាល ដែលមានការចូលរួមពីវិស័យឯកជន។

**មាត្រា៧.**_

រំហូរនៃនីតិវិធីនិងការអនុម័តការបំពេញផលហិរញ្ញវត្ថុ ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ប្រភពធនធាន និងការប្រើប្រាស់ ម.ប.ហ.

**មាត្រា៨.**_

**ម.ប.ហ.** មានប្រភពធនធានដូចតទៅ៖

- មូលធនដំបូងជាឥណទាន ដែលកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ការបែងចែកផលចំណេញ ផលចំណូល និងកម្រៃផ្សេងៗ ដែលរដ្ឋទទួលបានពីគម្រោង**ភ.រ.ជ.**
- ថវិកាពីដៃគូអភិវឌ្ឍនិងថវិកាពីគ្រប់ប្រភពស្របច្បាប់ផ្សេងៗទៀត។

ធនធានពីគ្រប់ប្រភពទាំងអស់ ដែលផ្តល់ឱ្យ**ម.ប.ហ.** ត្រូវរក្សាទុកក្នុងគណនីដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការបែងចែកថវិកាប្រចាំឆ្នាំសម្រាប់**ម.ប.ហ.** ត្រូវផ្អែកលើទំហំតម្រូវការនៃការបំពេញផលហិរញ្ញវត្ថុសរុបដូចមានចែងក្នុងកិច្ចសន្យា**ភ.រ.ជ.** ដែលសន្យាបំពេញដោយស្ថាប័នសាមីនីមួយៗ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវវិភាជថវិកាប្រចាំឆ្នាំ ដើម្បីទូទាត់ក្នុងឆ្នាំបន្ទាប់សម្រាប់ការបំពេញផលហិរញ្ញវត្ថុ។

**មាត្រា៩.**_

**ម.ប.ហ.** ត្រូវបានប្រើប្រាស់ក្នុងសកម្មភាព ដូចខាងក្រោម៖

- ផ្តល់ការបំពេញផលហិរញ្ញវត្ថុក្នុងទម្រង់ជាការឧបត្ថម្ភធនដោយផ្ទាល់ដល់ការចំណាយមូលធនក្រោមក្របខ័ណ្ឌគម្រោង**ភ.រ.ជ.** ដើម្បីបង្កើនផលចំណេញផ្នែកហិរញ្ញវត្ថុរបស់គម្រោងនោះចំពោះដៃគូឯកជន
- ផ្តល់ការគាំទ្រផ្នែកវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈគាំទ្រសម្រាប់គម្រោង**ភ.រ.ជ.** ឬគម្រោងអាទិភាពរបស់រាជរដ្ឋាភិបាលដែលមានការចូលរួមពីវិស័យឯកជន។

## ជំពូកទី៤
## ក្របខ័ណ្ឌក្នុងការប្រើប្រាស់ម.ប.ហ.

**មាត្រា១០._**

ទំហំនៃការបំពេញផលហិរញ្ញវត្ថុសម្រាប់គម្រោង**ភ.រ.ជ.** នីមួយៗ ត្រូវបានកំណត់ដោយឈរលើមូលដ្ឋានប្រកួតប្រជែងតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ទំហំអតិបរមានៃការបំពេញផលហិរញ្ញវត្ថុ សម្រាប់គម្រោង**ភ.រ.ជ.** នីមួយៗ មិនត្រូវលើសពី ៤០% (សែសិបភាគរយ) នៃទុនវិនិយោគគម្រោងសរុប។ ក្នុងករណីចាំបាច់ ស្ថាប័នសាមីអាចស្នើការពិនិត្យ និងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការបន្ថែមការបំពេញផលហិរញ្ញវត្ថុដោយប្រើប្រាស់ប្រភពធនធានស្របច្បាប់ផ្សេងទៀត ក្នុងទំហំមិនលើសពី ១០% (ដប់ភាគរយ) នៃទុនវិនិយោគគម្រោងសរុប។ ទំហំនៃការបំពេញផលហិរញ្ញវត្ថុខាងលើត្រូវកំណត់ជាការបំពេញផលហិរញ្ញវត្ថុរួមសម្រាប់ការគាំទ្រពីរដ្ឋ។

២- នៅក្នុងដំណាក់កាលអនុម័តគម្រោង រាជរដ្ឋាភិបាលត្រូវកំណត់ពិតាននៃការបំពេញផលហិរញ្ញវត្ថុទៅតាមគម្រោង**ភ.រ.ជ.** នីមួយៗ ដោយមិនត្រូវលើសពីទំហំ ដែលបានកំណត់ក្នុងវាក្យខណ្ឌទី១ នៃកថាខណ្ឌទី១ ខាងលើនេះ ផ្អែកលើការផ្តល់យោបល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយពិនិត្យលើពិតានថវិកានៃកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈសម្រាប់កម្មវិធី**ភ.រ.ជ.**។

៣- ស្ថាប័នសាមីត្រូវប្រើប្រាស់ពិតាននៃការបំពេញផលហិរញ្ញវត្ថុនេះ ជាមូលដ្ឋានក្នុងសំណើដេញថ្លៃដោយប្រកួតប្រជែង។ តម្រូវការបំពេញផលហិរញ្ញវត្ថុ ក្នុងសំណើរបស់អ្នកដេញថ្លៃណាដែលមានតម្លៃបច្ចុប្បន្នទាបបំផុត ត្រូវប្រើប្រាស់ជាលក្ខណវិនិច្ឆ័យចម្បងក្នុងការវាយតម្លៃសំណើហិរញ្ញវត្ថុ បន្ទាប់ពីការវាយតម្លៃសំណើបច្ចេកទេស។

៤- ទំហំនៃការបំពេញផលហិរញ្ញវត្ថុ ដែលទទួលបានការអនុម័តចុងក្រោយ មិនអាចត្រូវបានកែប្រែបានឡើយ លើកលែងក្នុងករណីដូចខាងក្រោម៖

ក- កិច្ចសន្យា**ភ.រ.ជ.** មានចែងនូវនីតិវិធី វិធីសាស្ត្រ និងលក្ខខណ្ឌ សម្រាប់ការកែប្រែដោយមិនត្រូវលើសពីទំហំអតិបរមាដូចមានកំណត់ក្នុងវាក្យខណ្ឌទី១ នៃកថាខណ្ឌទី១ ខាងលើនេះ ឬ

ខ- រាជរដ្ឋាភិបាលសម្រេចបង្កើនទំហំនៃការបំពេញផលហិរញ្ញវត្ថុក្រោមហេតុផលគោលនយោបាយសាធារណៈ ឬផលប្រយោជន៍ប្រទេសជាតិ ឬកាលៈទេសៈពិសេសណាមួយពាក់ព័ន្ធនឹងសកម្មភាពរាជរដ្ឋាភិបាល ដែលមានផលប៉ះពាល់លើផលចំណេញហិរញ្ញវត្ថុរបស់គម្រោង ដូចជាការធ្វើវិសោធនកម្មច្បាប់ ការកាត់បន្ថយកម្រៃដែលត្រូវទូទាត់ពីអ្នកប្រើប្រាស់ ឬករណីប្រហាក់ប្រហែលនានា។

**មាត្រា១១._**

ដើម្បីទទួលបានការបំពេញផលហិរញ្ញវត្ថុ គម្រោង**ភ.រ.ជ.** ត្រូវបំពេញតាមលក្ខណវិនិច្ឆ័យទាំងអស់ដូចខាងក្រោម៖

១- ជាគម្រោងផ្តួចផ្តើមដោយរដ្ឋ ដែលស្ថិតក្នុងវិស័យមានលក្ខណសម្បត្តិគ្រប់គ្រាន់ កំណត់ដោយច្បាប់ស្តីពី**ភ.រ.ជ.** និងមានយន្តការទូទាត់ផ្អែកលើផលចំណូលពីអ្នកប្រើប្រាស់។

២- ជាគម្រោង ដែលត្រូវប្រគល់ជូនមកស្ថាប័នសាមី ឬរាជរដ្ឋាភិបាលវិញ ក្រោយការបញ្ចប់កិច្ចសន្យា ឬការរំលាយកិច្ចសន្យា ផ្អែកលើខ និងលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចសន្យា**ភ.រ.ជ.**។

៣- ត្រូវមានទុនមូលធនអប្បបរមាស្មើ ២០% (ម្ភៃភាគរយ) នៃទុនវិនិយោគគម្រោងសរុបពីវិនិយោគិន នៅក្នុងក្រុមហ៊ុនមានគោលបំណងពិសេស។

៤- ត្រូវមានទុនមូលធនយ៉ាងតិច ៥១% (ហាសិបមួយភាគរយ) នៃទុនមូលធនសរុបពីដៃគូឯកជន នៅក្នុងក្រុមហ៊ុនមានគោលបំណងពិសេស។

៥- ដៃគូឯកជនជាសហគ្រាសសាធារណៈ ពុំអាចទទួលបានការបំពេញផលហិរញ្ញវត្ថុគម្រោង**ភ.រ.ជ.** ឡើយ លើកលែងតែសហគ្រាសសាធារណៈនោះជាវិនិយោគិនក្នុងគម្រោង**ភ.រ.ជ.** ជាមួយវិស័យឯកជន។

៦- បានសិក្សាសមិទ្ធិលទ្ធភាព ដែល៖

ក- រៀបចំឡើងដោយទីប្រឹក្សាប្រតិបត្តិការ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់

ខ- បង្ហាញថាគម្រោងមានតម្រូវការបំពេញផលហិរញ្ញវត្ថុ ដើម្បីបង្កើនផលចំណេញផ្នែកហិរញ្ញវត្ថុ

គ- បានគិតគូរលើគ្រប់ជម្រើសទាំងអស់ក្នុងការបង្កើនប្រសិទ្ធភាព នៃការអនុវត្តគម្រោង

ឃ- បានពិនិត្យច្បាស់លាស់នូវរាល់វិធីសាស្ត្រក្នុងការបង្កើនប្រាក់ចំណូលគម្រោង តាមរយៈការប្រមូលកម្រៃពីអ្នកប្រើប្រាស់ និង/ឬប្រភពចំណូលផ្សេងទៀត ក្នុងកម្រិតដែលអ្នកប្រើប្រាស់ និងរាជរដ្ឋាភិបាល អាចទទួលយកបានទាំងទិដ្ឋភាពសង្គម និងសេដ្ឋកិច្ច

ង- រួមបញ្ចូលការវាយតម្លៃតម្រូវការទីផ្សារ និងប្រភពចំណូល ដែលមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ

ច- បានគិតគូរលើគ្រប់ទិដ្ឋភាពក្នុងការប្រើប្រាស់មូលធន និងចំណាយប្រតិបត្តិការឱ្យមានប្រសិទ្ធភាព និងសមហេតុផល

ឆ- បង្ហាញពីការបែងចែកហានិភ័យរវាងរាជរដ្ឋាភិបាល ស្ថាប័នសាមី និងវិនិយោគិន ដើម្បីធានាចីរភាពហិរញ្ញវត្ថុសាធារណៈ

ជ- បានសន្និដ្ឋានថា គម្រោងមានសមិទ្ធិលទ្ធភាពផ្នែកបច្ចេកទេស ច្បាប់ ហិរញ្ញវត្ថុ បរិស្ថាន និងសង្គម សមាមាត្រនឹងទំហំតម្រូវការការបំពេញផលហិរញ្ញវត្ថុ។

៧- ត្រូវបានពិនិត្យ និងវាយតម្លៃលើទំហំស្នើសុំការបំពេញផលហិរញ្ញវត្ថុឱ្យបានច្បាស់លាស់ ម៉ត់ចត់ និងត្រឹមត្រូវ ដោយផ្អែកលើលទ្ធភាពថវិកា។

៨- មានលទ្ធភាពខ្ពស់ក្នុងការទទួលបានហិរញ្ញប្បទាន ក្នុងករណីរាជរដ្ឋាភិបាលផ្តល់ការបំពេញផលហិរញ្ញវត្ថុ។

**មាត្រា១២._**

ចំពោះគម្រោង**ភ.រ.ជ.** ឬគម្រោងអាទិភាពរបស់រាជរដ្ឋាភិបាលដែលមានការចូលរួមពីវិស័យឯកជន ដែលត្រូវបានវាយតម្លៃថាមានតម្រូវការការគាំទ្រផ្នែកវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈដោយឡែកពីការបំពេញផលហិរញ្ញវត្ថុ នឹងត្រូវពិនិត្យ និងសម្រេចដោយរាជរដ្ឋាភិបាលស្របតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នីតិវិធីនៃការទូទាត់ការគាំទ្រផ្នែកវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់គម្រោង**ភ.រ.ជ.** ឬគម្រោងអាទិភាពរបស់រាជរដ្ឋាភិបាលដែលមានការចូលរួមពីវិស័យឯកជន នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# ជំពូកទី៥
# ការទូទាត់

**មាត្រា១៣._**

ក្រុមហ៊ុនមានគោលបំណងពិសេសត្រូវបង្កើតគណនីធនាគារសម្រាប់ការទូទាត់ការបំពេញផលហិរញ្ញវត្ថុ ដែលជាប្រភេទគណនីរក្សាទុក ដោយឡែកពីគណនីប្រតិបត្តិការផ្សេងទៀតនៅធនាគារ ដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពីនិយ័តករពាក់ព័ន្ធ និងមានទីតាំងស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការទូទាត់ការបំពេញផលហិរញ្ញវត្ថុត្រូវបង់ជាដំណាក់កាលទៅតាមការសម្រេចបង្គោលចរសមិទ្ធផលការងារដែលសម្រេចបានដោយក្រុមហ៊ុនមានគោលបំណងពិសេស នៅក្រោយពេលការងារសាងសង់បានចាប់ផ្តើម និងអាចបន្តយូរបំផុតត្រឹម ២ (ពីរ) ឆ្នាំ ក្រោយពេលការងារសាងសង់បានបញ្ចប់ជាស្ថាពរ។ បង្គោលចរសមិទ្ធកម្មទាំងនេះ ត្រូវផ្អែកលើខ និងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យា**ភ.រ.ជ.**។

ការទូទាត់ការបំពេញផលហិរញ្ញវត្ថុត្រូវចាប់ផ្តើមបន្ទាប់ពីលក្ខខណ្ឌខាងក្រោមទាំងអស់ត្រូវបានបំពេញ៖

១- កិច្ចព្រមព្រៀងពាក់ព័ន្ធត្រូវបានចុះហត្ថលេខារវាងវិនិយោគិន និងធនាគារផ្តល់ប្រាក់កម្ចី ដែលបានប្តេជ្ញាចូលរួមវិនិយោគក្រោមទម្រង់ជាទុនមូលធន បំណុល ឬទម្រង់ផ្សេងទៀត ក្នុងទុនវិនិយោគគម្រោងសរុបនៃគម្រោង**ភ.រ.ជ.** ដោយមិនរាប់បញ្ចូលនូវការបំពេញផលហិរញ្ញវត្ថុ។

២- វិនិយោគិនបានដាក់ទុនចំនួន ៥០% (ហាសិបភាគរយ) នៃទុនមូលធនសរុបរបស់គម្រោង**ភ.រ.ជ.** ទៅក្នុងគណនីរបស់ក្រុមហ៊ុនមានគោលបំណងពិសេស។

៣- ឥណទានដំណាក់កាលដំបូងដែលផ្តល់ដោយឥណទាយកថ្នាក់ខ្ពស់ ត្រូវបានដាក់បញ្ចូលក្នុងគណនីរបស់ក្រុមហ៊ុនមានគោលបំណងពិសេស។

ការទូទាត់ការបំពេញផលហិរញ្ញវត្ថុនីមួយៗត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១- ក្រុមហ៊ុនមានគោលបំណងពិសេសត្រូវដាក់សំណើសុំទូទាត់ការបំពេញផលហិរញ្ញវត្ថុរបស់ខ្លួនជូនទីប្រឹក្សាឯករាជ្យ។

២- ទីប្រឹក្សាឯករាជ្យត្រូវពិនិត្យវឌ្ឍនភាពការងារ និង/ឬបង្គោលចរសមិទ្ធកម្មផ្សេងទៀត និងរៀបចំរបាយការណ៍ជូនស្ថាប័នសាមី ដូចបានកំណត់ក្នុងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គម្រោង**ភ.រ.ជ.**។

៣- ស្ថាប័នសាមីត្រូវដាក់ការស្នើសុំការអនុម័តលើការទូទាត់ការបំពេញផលហិរញ្ញវត្ថុ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិនិត្យលើការស្នើសុំទូទាត់ការបំពេញផលហិរញ្ញវត្ថុ និងអនុម័តលើការទូទាត់ពីគណនី**ម.ប.ហ.** ទៅក្នុងគណនីធនាគាររបស់ក្រុមហ៊ុនមានគោលបំណងពិសេស ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៤._**

ការទូទាត់ការបំពេញផលហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗត្រូវស្ថិតក្នុងទំហំកញ្ចប់ថវិកាជាតិប្រចាំឆ្នាំ និង/ឬទំហំហិរញ្ញប្បទានស្របច្បាប់ដទៃទៀត។

## ជំពូកទី៦
## ការទទួលបានមកវិញនូវការបំពេញផលហិរញ្ញវត្ថុ

**មាត្រា១៥._**

ក្នុងករណីមានការរំលាយកិច្ចសន្យាគម្រោង**ភ.រ.ជ.** មុនកាលកំណត់ ទំហំនៃការបំពេញផលហិរញ្ញវត្ថុ ដែលរដ្ឋបានបើកផ្ដល់ជូនដៃគូឯកជន តាមខ និងលក្ខខណ្ឌនៃកិច្ចសន្យាគម្រោង**ភ.រ.ជ.** អាចត្រូវប្រើជាឥណទានសម្រាប់កាត់កងសំណងរបស់រដ្ឋក្នុងការទិញគម្រោងពីដៃគូឯកជនមកវិញ ផ្អែកតាមរូបមន្ត ដែលបានចែងលម្អិតក្នុងកិច្ចសន្យា**ភ.រ.ជ.**។

**មាត្រា១៦._**

លក្ខខណ្ឌសម្រាប់កំណត់ការសងមកវិញនៃការបំពេញផលហិរញ្ញវត្ថុ រូបមន្តក្នុងគណនាសំណង ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗត្រូវបំពេញសម្រាប់ការរំលាយកិច្ចសន្យាមុនកាលកំណត់ ត្រូវចែងលម្អិតនៅក្នុងកិច្ចសន្យា**ភ.រ.ជ.**។

## ជំពូកទី៧
## គណនេយ្យ និងសវនកម្ម

**មាត្រា១៧._**

ការទូទាត់ការបំពេញផលហិរញ្ញវត្ថុសម្រាប់គម្រោង**ភ.រ.ជ.** និងការគាំទ្រផ្នែកវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់គម្រោង**ភ.រ.ជ.** ឬគម្រោងអាទិភាពរបស់រាជរដ្ឋាភិបាល ដែលមានការចូលរួមពីវិស័យឯកជន ត្រូវកត់ត្រាជាចំណាយមូលធនរបស់ស្ថាប័នសាមី អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៨._**

ក្រុមហ៊ុនមានគោលបំណងពិសេស ដែលទទួលបានការបំពេញផលហិរញ្ញវត្ថុ ត្រូវចាត់ចែងរៀបចំកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍ឆ្លុះបញ្ចាំងពីការអនុវត្តគម្រោង**ភ.រ.ជ.** ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

របាយការណ៍សវនកម្មប្រចាំឆ្នាំរបស់ក្រុមហ៊ុនមានគោលបំណងពិសេសត្រូវរៀបចំដោយសវនករឯករាជ្យ ដើម្បីពិនិត្យលើអនុលោមភាព និងទិដ្ឋភាពជាក់ស្ដែងនៃស្ថានភាព និងការគ្រប់គ្រងហិរញ្ញវត្ថុនៃគម្រោង**ភ.រ.ជ.**។ របាយការណ៍សវនកម្មត្រូវមានរួមបញ្ចូល ថ្លៃដើមគម្រោង បំណុល ភាគហ៊ុន ការបំពេញផលហិរញ្ញវត្ថុនិងហិរញ្ញប្បទានផ្សេងទៀតរបស់គម្រោង**ភ.រ.ជ.**។

**មាត្រា១៩._**

ស្ថាប័នសាមីត្រូវរងការធ្វើសវនកម្មតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ស្ថាប័នសាមីត្រូវទទួលខុសត្រូវលើការរៀបចំរក្សាទុកឯកសារនៃដំណើរការកិច្ចលទ្ធកម្ម។ ឯកសារពាក់ព័ន្ធទាំងអស់ត្រូវរក្សាទុកជាសំណុំឯកសារ ដែលមានភាពគ្រប់ជ្រុងជ្រោយ និងអាចប្រើប្រាស់បានដោយស្ថាប័នសាមី ឬភាគី ដែលមានសិទ្ធិប្រើប្រាស់ឯកសារនោះ។

ការធ្វើសវនកម្មត្រូវផ្ដោតទៅលើការគ្រប់គ្រងហិរញ្ញវត្ថុ និងអនុលោមភាពនៃនីតិវិធី ដែលពាក់ព័ន្ធនឹងការទូទាត់ការបំពេញផលហិរញ្ញវត្ថុនិងការគាំទ្រផ្នែកវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់គម្រោង**ភ.រ.ជ.** ឬគម្រោងអាទិភាពរបស់រាជរដ្ឋាភិបាល ដែលមានការចូលរួមពីវិស័យឯកជន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២០._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១ រោច ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា២១
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ២៣៨អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២៤
# ស្ដីពីការគ្រប់គ្រងមូលនិធិបំពេញផលហិរញ្ញវត្ថុ
# សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន
# រំហូរនៃនីតិវិធី និងការអនុម័តការបំពេញផលហិរញ្ញវត្ថុ

